ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស ៥ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំ **មមែ** សប្តស័ក ព.ស ២៥៥៩ គ.ស ២០១៥ នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកមានទេវតាឆ្នាំថ្មី សូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាទីគោរពដ៏ខ្ពង់ខ្ពស់ ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ និងទទួលបានជោគជ័យថ្មីៗ ថែមទៀត ក្នុងបេសកកម្មដឹកនាំរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនសម្បូររុងរឿងប្រកបដោយសុភមង្គល។ **សម្តេច** បានដឹកនាំកសាងពង្រឹងកងយោធពល-ខេមរភូមិន្ទលើគ្រប់វិស័យ ការពារបានរឹងមាំគង់វង្ស នូវបូរណភាពទឹកដី ធ្វើឲ្យប្រទេសជាតិទទួលបាននូវសុខសន្តិភាព ឯករាជ្យ និងអភិវឌ្ឍន៍មាតុភូមិកម្ពុជាឲ្យបានថ្កុំថ្កើងសម្បូររុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្លែងក្នុងពិធីបិទសិក្ខាសាលា បូកសរុបការងារកែទម្រង់ ៥ ឆ្នាំ និងទិសដៅអនុវត្ត ៥ ឆ្នាំ បន្តនៅក្រសួងការពារជាតិ **កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ថ្មីៗ នេះ សម្តេច** បានផ្តល់អនុសាសន៍ដ៏មានសារៈសំខាន់ ៩ ចំណុច និងយុទ្ធសាស្ត្រ ៣ សកម្មភាពប្រតិបត្តិការ និងអភិវឌ្ឍន៍ ១០ ដល់កងយោធពលខេមរភូមិន្ទ បានធ្វើឲ្យយើងខ្ញុំទាំងអស់គ្នាចងចាំជានិច្ច និងអនុវត្តកែទម្រង់ស៊ីជម្រៅ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មេបញ្ជាការគ្រប់ជាន់ថ្នាក់ នាយទាហាន នាយទាហានរង និងពលទាហាន សូមប្តេជ្ញាគាំទ្រ ការពាររដ្ឋធម្មនុញ្ញ ការពាររាជរដ្ឋាភិបាលស្របច្បាប់ និងមិនអនុញ្ញាតឲ្យអ្នកណាបំផ្លាញកម្ពុជាបានឡើយ។

វិថីហ្សកឌឺមីគ្រែវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh

ក្នុងពេលនេះ ថ្វីបើសភាពការណ៍នៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ មានសភាពការណ៍ស្ងប់ស្ងាត់បន្តិចក៏ដោយ ក៏ **សម្តេចតេជោ** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅតែយកចិត្តទុកដាក់លើកទឹកចិត្ត សាកសួរសុខទុក្ខ ផ្តល់អំណោយដល់កងយោធពលខេមរភូមិន្ទ នៅតាមខ្សែបន្ទាត់ព្រំដែនជាប់ជានិច្ច។ នេះសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា **សម្តេចទាំងពីរ** តែងតែនៅជាប់ជាមួយកងយោធពលខេមរភូមិន្ទ និងធ្វើឲ្យយើងខ្ញុំទាំងអស់គ្នា ប្តេជ្ញាការពារបូរណភាពទឹកដី អធិបតេយ្យភាពជាតិកម្ពុជាមិនឲ្យបាត់បង់ឡើយ។

តាមរយៈជោគជ័យនេះកងយោធពលខេមរភូមិន្ទ និងប្រជាជនកម្ពុជាទូទាំងប្រទេស មើលឃើញកាន់តែច្បាស់ថែមទៀត នូវតួនាទីដែលមិនអាចខ្វះបានរបស់ **សម្តេច** ទាំងពេលបច្ចុប្បន្ន និងអនាគត ក្នុងការដឹកនាំមាតុភូមិកម្ពុជាឲ្យមានការរីកចម្រើនលើគ្រប់វិស័យ  សូមគាំទ្របេក្ខភាពរបស់ **សម្តេច** ជានាយករដ្ឋមន្ត្រីសម្រាប់អាណត្តិក្រោយៗ ទៀត។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស ៥ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**